ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 01 / 2015
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**ពី៖** ចៅក្រម និល ណុន
ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

E.C.C.C * C.E.T.C * TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE

**ចម្លងជូន៖** លោក លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២

**កម្មវត្ថុ៖** ការបញ្ជូនសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានចំណងជើងថា "ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច"

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") គឺជាតុលាការមួយដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បច្ចុប្បន្ននេះបានទទួលសំណុំរឿង ០០២ រួមមាន លោក ខៀវ សំផន ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ អង្គជំនុំជម្រះសូមភ្ជាប់ជូននូវក្របខ័ណ្ឌគតិយុត្តិនៃ អ.វ.ត.ក ដូចមានខាងក្រោម សម្រាប់ជាឯកសារយោង៖

- ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក៖ http://www.eccc.gov.kh/sites/default/files/legal-documents/KR_Law_as_amended_27_Oct_2004_Kh__Combination_.pdf

- វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក៖ http://www.eccc.gov.kh/document/legal/15232

លោក គង់ សំអុន ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គឺជាមេធាវីតំណាងឲ្យលោក ខៀវ សំផន នៅក្នុងសំណុំរឿង ០០២។ សំណុំរឿង ០០២ ត្រូវបានបំបែកទៅជាការជំនុំជម្រះពីរផ្នែកដាច់ដោយឡែកពីគ្នា ដោយផ្នែកនីមួយៗដោះស្រាយផ្នែកផ្សេងៗនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ការជំនុំជម្រះផ្នែកទីមួយ គឺសំណុំរឿង ០០២/០១ បានបញ្ចប់រួចហើយ ហើយបានចេញសាលក្រមប្រឆាំងលោក ខៀវ សំផន និងសហជនជាប់ចោទរបស់គាត់ គឺលោក នួន ជា កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ ព័ត៌មានបន្ថែមទៀតអំពីសំណុំរឿង ០០២ អាចមាននៅក្នុងឯកសារដូចខាងក្រោម៖

- ដីកាដំណោះស្រាយសំណុំរឿង ០០២៖ http://www.ecc.gov.kh/document/court/14885
- សាលក្រមសំណុំរឿង ០០២/០១៖ http://www.eccc.gov.kh/document/court/30547

សវនាការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ បានគ្រោងចាប់ផ្ដើមធ្វើឡើងនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ។ នៅថ្ងៃនោះ មេធាវីការពារក្ដី ខៀវ សំផន បានបង្ហាញថា ពួកគាត់មិនមានបំណងចូលរួមកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ ទេ រហូតទាល់តែពួកគាត់បានដាក់សារណាបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ រួចរាល់សិន ។ បន្ទាប់មក មេធាវីការពារក្ដីបានចាកចេញពីបន្ទប់សវនាការ ហើយក្រោយមក អង្គជំនុំជម្រះបានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលតាមជនជាប់ចោទ និងមានការបង្គាប់យ៉ាងច្បាស់លាស់ឲ្យមេធាវីរបស់ជនជាប់ចោទចូលរួមក្នុងតុលាការក៏ដោយ ក៏អង្គជំនុំជម្រះ នៅតែជួបប្រទះបញ្ហាការបដិសេធមិនព្រមចូលរួមកិច្ចដំណើរការនីតិវិធីសវនាការ និងមិនមានកិច្ចសហការពីមេធាវីការពារក្ដី ដែលបញ្ហានេះបានបង្ខំឲ្យអង្គជំនុំជម្រះផ្អាកកិច្ចដំណើរការនីតិវិធីសវនាការហូតដល់ ខែ មករា ឆ្នាំ ២០១៥ ។ ដើម្បីចៀសវាងកុំឲ្យមានស្ថានភាពនេះកើតឡើងម្ដងទៀតនាពេលអនាគត អង្គជំនុំជម្រះបានបង្គាប់ឲ្យមានការតែងតាំងមេធាវីប្រចាំការជាតិម្នាក់ និងអន្តរជាតិម្នាក់សម្រាប់ ខៀវ សំផន[1]។

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានសម្រេចថា ការរំលោភបំពានរបស់មេធាវីការពារក្ដី ខៀវ សំផន ទៅលើដីកាបង្គាប់របស់តុលាការឲ្យចូលរួមសវនាការដែលបានគ្រោងទុក បានធ្វើឲ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីសវនាការដែលតម្រូវឲ្យមានការដាក់ទណ្ឌកម្ម អនុលោមតាមវិធាន ៣៨ នៃវិធាន

[1]សេចក្ដីសម្រេចស្ដីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ឯកសារ E321/2 ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៤។

ផ្ទៃក្នុងរបស់ អ.វ.ត.ក[2]។ រហូតមកដល់ពេលនេះ ការបដិសេធរបស់មេធាវីការពារក្តីមិនចូលរួមសវនាការរបស់តុលាការ បានធ្វើឱ្យបាត់បង់ពេលវេលាសវនាការចំនួន ២៥ ថ្ងៃ ក្នុងរយៈពេល ១០ សប្តាហ៍។ អង្គជំនុំជម្រះបានដោះស្រាយ ហើយនឹងបន្តដោះស្រាយកំហុសវិជ្ជាជីវៈនេះតាមវិធានផ្ទៃក្នុងរបស់ខ្លួន ។ ទោះបីជាបែបនេះក្តី ដោយពិនិត្យឃើញថា ការប្រព្រឹត្តិរបស់មេធាវីរូបនេះ ក៏ជាប់ពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែរនោះ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចបញ្ជូនការប្រព្រឹត្តិរបស់មេធាវី គង់ សំអុន ទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យក្រុមប្រឹក្សាគណៈមេធាវីចាត់វិធានការតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ក្រមសីលធ៌មមេធាវីនៃគណៈមេធាវី និងបទប្បញ្ញត្តិគតិយុត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមថ្លែងអំណរគុណទុកជាមុន ប្រសិនបើគណៈមេធាវីកម្ពុជាអាចជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះក្នុងពេលវេលាសមស្រប អំពីលទ្ធផលនៃការបញ្ជូនកំហុសវិជ្ជាជីវៈ និងការចាត់វិធានការណាមួយទៅលើកំហុសវិជ្ជាជីវៈនេះ ។

សូមជូនភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធមួយចំនួនសម្រាប់ជាជំនួយដល់ការពិនិត្យ និងពិចារណារបស់គណៈមេធាវីកម្ពុជា។ ប្រសិនបើគណៈមេធាវីមានសំណួរ ឬ ត្រូវការនូវព័ត៌មានពាក់ព័ន្ធបន្ថែមទៀត សូមទាក់ទងមកលោក Ken Roberts មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក តាមរយៈអាសយដ្ឋានអ៊ីម៉ែល roberts13@un.org

[2] ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ឯកសារ E330 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ២៩-៣១។